២-សមាគម **កាស៊ីវ៉ា ឡៃអុិនក្លឹប** KASHIWA LIONSCLUB ជួយកសាងសាលារៀនមួយខ្នងបំពាក់សង្ការឹម សូនច្បារ ក្លោងទ្វារ នៅសាលាបឋមសិក្សា សោម ឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ ដោយចំណាយថវិកាសរុប ២៩.៤៣៦ ដុល្លារអាមេរិក ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

❀❀❀

## III-**ការងារបណ្តាក្រសួង**

## **ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

## **ប្រកាស**

រាជធានីភ្នំពេញ. ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១

**ប្រកាសលេខ ០៤០ បទ.ប្រក**

**ស្តីពីសេវាជួលខ្សែបរិមាណទូរគមនាគមន៍អក្ខរលេខ**

( Digital Leased Capacity )

----

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៦៦អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃ ០៥ ខែ មិថុនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីប្រៃសណីយ៍និងទូរគមនាគមន៍

-បានឃើញសេចក្តីសំរេចលេខ ១៩៤ សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រម គ្រប់គ្រងតម្លៃ

-យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីអំពីការកែប្រែតម្លៃសំរាប់សេវាកម្មទូរគមនាគមន៍ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** កំណត់ថ្លៃសេវាជួលជាវបរិបថទូរគមនាគមន៍អក្ខរៈលេខក្នុងក្រុង រយៈផ្លូវឆ្ងាយក្នុងប្រទេស និងអន្តរជាតិ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

**ប្រការ ២ :** រាល់បញ្ញត្តិនៃប្រកាសទាំងឡាយណាដែលមានចំណុចផ្ទុយជាមួយចំណុច នៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងបណ្តាអង្គភាពប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត-ក្រុង ក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

**ប្រការ ៤ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សូ ឃុន**

៙៙៙

## ឧបសម្ព័ន្ធទី ១ ភ្ជាប់
## ប្រកាសលេខ ០៨០ បន.ប្រក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១
## ថ្លៃសេវាជួលខ្សែបរិបថទូរគមនាគមន៍អក្ខរៈលេខ
( tariff of Digiatl Leased Capacity )
## ចាប់អនុវត្តន៍ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០១

----

### ១.ការប្រើប្រាស់បណ្តាញទូរគមនាគមន៍អក្ខរៈលេខសំរាប់សេវាក្នុងប្រទេស :

១.១-ការជួលជាអប្បបរមា Minimum Lease ស្មើចំណុះល្បឿន 1xE1 ( ៣០ បរិបថទូរ ស័ព្ទ) និងរយៈពេលមួយឆ្នាំ ។ ចំណុះ 1xE1 ឬ NxE1 អាចបានត្រូវផ្គត់ផ្គង់ក្នុងរយៈផ្លូវនៃបណ្តាញ ឬ កំណាត់បណ្តាញដោយចេញពីចំណុចម្ខាង ឬចូលទៅចំណុចម្ខាង ឬពីចំណុចមួយទៅ ចំណុច មួយ ។

១.២-ថ្លៃជួលជាវបានត្រូវអនុវត្តសរុបតាមរចនាសម្ព័ន្ធដូចខាងក្រោម :

១.២.១- ថ្លៃបើកផ្លូវគ្រាដំបូង ចំណុចម្ខាង ( Access Charge/one end )

១.២.១.១- ចំណុះល្បឿន 1xE1=250$

១.២.១.២- ចំណុះល្បឿន 4xE1=750 $

១.២.២- ថ្លៃជួលជាវប្រចាំខែ ( Monthly Charges ) បានត្រូវអនុវត្តផ្អែកតាមចំណុះល្បឿន ចម្ងាយរយៈផ្លូវមានបី ( 3 ) របៀប

១.២.២.១-តប្រគំត្រង់រវាងចំណុចចេញ និងចំណុចចូល :

ថ្លៃត្រូវបង់តាមតារាង MATRIX ដូចខាងក្រោម ។

១.២.២.២- ភ្នំពេញ : តប្រគំដោយប្រើបរិបថ តពន្លាតជាបណ្តាញក្រុងមានស្រាប់ ថ្លៃ បន្ថែម 450$E1

១.២.២.៣- ខេត្ត : តប្រគំដោយប្រើបរិបថតពន្លាតជាបណ្តាញក្រុងមានស្រាប់ ថ្លៃ បន្ថែម 350$ E1

១.៣-ការបញ្ចុះថ្លៃលើទឹកប្រាក់សរុបបង់ប្រចាំខែ :

១.៣.១- ពី 10>000 ក្រោម 30,000$ បង់ត្រឹម 97%

១.៣.២- ពី 30,000 ក្រោម 50000$ បង់ត្រឹម 95%

១.៣.៣- ពី 50.000$ ឡើង បង់ត្រឹម 93%

**២-ការប្រើប្រាស់សេវាជួលខ្សែបរិបថអក្សរលេខក្នុងក្រុង** ( Local Lease )

**បណ្ដាញ ក្រុង មានស្រាប់ ថ្លៃបង់តាមរចនាសម្ព័ន្ធ ដូចខាងក្រោម :**

២.១- ថ្លៃបើកផ្លូវគ្រាដំបូង ចំណុចម្ខាង ( Access Charge/one end )

២.១.១- ចំណុះល្បឿនរហូត 256Kbps =125$

២.១.២- ចំណុះល្បឿនរហូត 2,048Kbps =250$

២.១.៣- ចំណុះល្បឿនស្មើ 8Mbps = 750$

២.២- ថ្លៃជួលជាប្រចាំខែ តភ្ជាប់ត្រង់ រវាងចំណុចចេញ និងចំណុចចូល :

២.២.១- ចំណុះល្បឿន 2.4-9.6Kbps = 44$

២.២.២- ចំណុះល្បឿន 19.2Kbps = 96$

២.២.៣- ចំណុះល្បឿន 64Kbps = 122$

២.២.៤- ចំណុះល្បឿន 128Kbps = 192$

២.២.៤- ចំណុះល្បឿន 256Kbps = 263$

២.២.៦- ចំណុះល្បឿន 512Kbps = 324$

២.២.៧- ចំណុះល្បឿន 1,024Kbps = 540$

២.២.៨- ចំណុះល្បឿន 1,536Kbps = 720$

២.២.៩- ចំណុះល្បឿន 2,048Kbps = 900$

២.៣-ការស្ថាបនាតប្រតំរវាងទីតាំងប្រើប្រាស់ ជាបន្ទុករបស់អតិថិជន ឬដោយជួលជាខ្សែ និងបរិបថ ដោយឡែក :

**២.៣.១-ថ្លៃជួលខ្សែកាប្លិ៍** ( Leased Line ) **រវាងចំណុច** mdf

២.៣.១.១- ខ្សែមួយគូ ( 2W ) = 150 $/ មួយខែ

២.៣.១.២- ខ្សែពីរគូ ( 4W ) = 225 $/ មួយខែ

២.២.២- ថ្លៃស្ថាបនាខ្សែកាប្លិ៍គិតតាមសារណាការរវាងចំណុច MDF

២.៣.២.១- ខ្សែមួយគូ ( 2W ) = គិតអប្បបរមា 200$

២.៣.២.២- ខ្សែពីរគូ ( 4W ) គិតអប្បបរមា = 300$

**៣.ការប្រើប្រាស់បណ្តាញសំរាប់សេវាអន្តរជាតិ :**

សេវាបានត្រូវផ្តត់ផ្គង់រវាងប្រទេសវៀតណាម និងប្រទេសថៃ ចំពោះក្រុមហ៊ុនការីបណ្តាញទូរ គមនាគមន៍ដែលជាប់កិច្ចសន្យាសហប្រតិបត្តិការពាណិជ្ជកម្ម ( BCC ) និងអតិថិជនដែលមានការ អនុញ្ញាតប្រើប្រាស់ឯកជន បូបំរើសាធារណៈ ។

៣.១-បានត្រូវអនុវត្តល័ក្ខខ័ណ្ឌត្រង់ចំណុច ១.១ និងថ្លៃបើកផ្លូវគ្រាដំបូងត្រង់ចំណុច ១.២ ដូច ខាងលើ ។

៣.២-ថ្លៃជួលជាប្រចាំខែ តាមចំណុះល្បឿន និងចម្ងាយរយៈផ្លូវរវាងព្រំប្រទល់ប្រទេសបានត្រូវអនុវត្តតាមតារាង MATRIX ដូចខាងក្រោម ។

**៤.ការប្រើប្រាស់បរិបថអក្ខរៈលេខតាមប្រព័ន្ធស្ថានីយ៍ផ្កាយរណបអន្តរជាតិ :**

សេវាបានត្រូវផ្គត់ផ្គង់ចំពោះអតិថិជនដែលមានការអនុញ្ញាតប្រើប្រាស់ឯកជន បូបំរើសាធារណៈ ។

ថ្លៃប្រើប្រាស់ប្រចាំខែ និងថ្លៃស្ថាបនាគ្រាដំបូងរវាងមជ្ឈមណ្ឌលមាត់ច្រក អន្តរជាតិគិតតាមចំណុះល្បឿន :

៤.១- ចំណុះល្បឿន 2.4Kbps = 1,400$ / ខែ ថ្លៃស្ថាបនា = 800$

៤.២- ចំណុះល្បឿន 4.8Kbps = 2,400$ / ខែ ថ្លៃស្ថាបនា = 1,000$

៤.៣- ចំណុះល្បឿន 9.6Kbps = 3,100$ / ខែ ថ្លៃស្ថាបនា = 1,300$

៤.៤- ចំណុះល្បឿន 19.2Kbps = 3800$ / ខែ ថ្លៃស្ថាបនា = 1,600$

៤.៥- ចំណុះល្បឿន 48 ឬ 56 ឬ 64Kbps = 5,000$ / ខែ ថ្លៃស្ថាបនា = 2,000$

៤.៦- ចំណុះល្បឿន 128Kbps = 8000$ / ខែ ថ្លៃស្ថាបនា = 2,400$

៤.៧- ចំណុះល្បឿន 192Kbps = 9,900$ / ខែ ថ្លៃស្ថាបនា = 2,800$

៤.៨- ចំណុះល្បឿន 256Kbps = 12,000$ / ខែ ថ្លៃស្ថាបនា = 3,000$

៤.៩- ចំណុះល្បឿន 384Kbps = 15,400$ / ខែ ថ្លៃស្ថាបនា = 3,500$

៤.១០- ចំណុះល្បឿន 512Kbps = 18,000$ / ខែ ថ្លៃស្ថាបនា = 4,000$

៤.១១- ចំណុះល្បឿន 768Kbps = 26,600$ / ខែ ថ្លៃស្ថាបនា = 4,500$

៤.១២- ចំណុះល្បឿន 1,024Kbps = 30,000$ / ខែ ថ្លៃស្ថាបនា = 5,000$

៤.១៣- ចំណុះល្បឿន1,544Kbps = 39,200$ / ខែថ្លៃស្ថាបនា = 6,000$

៤.១៤- ចំណុះល្បឿន 2,048Kbps = 45000$ / ខែថ្លៃស្ថាបនា = 6,500$

## តារាង MATRIX

## ថ្លៃប្រចាំខែ តាមរបៀបតម្រូតគ្រង់ រវាងចំណុចចេញ និងចំណុចចូល

**Monthly Lease Between Originating Terminating Points**

ចំណុះល្បឿន ១ X E1 គិតជាប្រាក់ដុល្លារមួយខែ ( USD )

| Orig Term points | | Viet nam | Thai land | Bavet | Svay Rieng | Neak Loueng | Phnom Penh | Kg Ch hnang | Pur sat | Battam bang | Siso Phon | Poipet |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Vietnam | | 10,271 | 5,279 | 5,641 | 6,191 | 6,700 | 7,504 | 8,342 | 9,261 | 9,852 | 10,271 |
| 2 | Thailand | 10,271 | | 10,271 | 9,910 | 9,360 | 8,851 | 8,046 | 7,225 | 6,289 | 5,698 | 5,279 |
| 3 | Bavet | 5,279 | 10,271 | | 1,366 | 1,916 | 2,425 | 3,229 | 4,067 | 4,986 | 5,577 | 5,996 |
| 4 | Svayrieng | 5,641 | 9,910 | 1,366 | | 1,554 | 2,063 | 2,868 | 3,705 | 4,625 | 5,216 | 5,635 |
| 5 | Neakloeung | 6,191 | 9,360 | 1,916 | 1,554 | | 1,513 | 2,318 | 3,155 | 4,075 | 4,666 | 5,085 |
| 6 | P.Penh | 6,700 | 8,851 | 2,425 | 2,063 | 1,513 | | 1,809 | 2,646 | 3,566 | 4,157 | 4,576 |
| 7 | Kg.Chhnang | 7,504 | 8,046 | 3,229 | 2,868 | 2,318 | 1,809 | | 1,842 | 2,761 | 3,352 | 3,771 |
| 8 | Pursat | 8,342 | 7,225 | 4,069 | 3,705 | 3,155 | 2,646 | 1,842 | | 1,924 | 2,515 | 2,934 |
| 9 | Battambang | 9,261 | 6,289 | 4,986 | 4,625 | 4,075 | 3,566 | 2,761 | 1,924 | | 1,595 | 2,014 |
| 10 | Sisophon | 9,852 | 5,698 | 5,577 | 5,216 | 4,666 | 4,157 | 3,352 | 2,515 | 1,595 | | 1,423 |
| 11 | Poipet | 10,271 | 5,279 | 5,996 | 5,635 | 5,085 | 4,576 | 3,771 | 2,934 | 2,014 | 1,423 | |

**កំណត់សំគាល់** : ឥតបានគិតបញ្ចូលថ្លៃអាករ VAT .

## អត្ថន័យ និងល័ក្ខខ័ណ្ឌសេវាជួលបរិបថទូរគមនាគមន៍អក្ខរៈលេខ

**( Terms and Conditions of Digial Leased Capacity )**

ផ្អែកតាមលទ្ធផលនៃកិច្ចអភិវឌ្ឍន៍បណ្តាញទូរគមនាគមន៍អក្ខរៈលេខឆ្នាំ ១៩៩៨-១៩៩៩ ក្រសួង ប្រៃសណីយ៍និងទូរគមនាគមន៍ បានបើកសេវាបំរើការជួលជាវ បរិបថអក្ខរៈលេខមាន ចំណុះល្បឿន និង ប្រសិទ្ធភាពខ្ពស់ សំរាប់ភ្ជាប់គមនាគមន៍ពតិមានគ្រប់ប្រភេទក្នុងទីក្រុង ទីរួមខេត្ត និងរយៈផ្លូវឆ្ងាយ "ព្រំប្រទល់ប្រទេសថៃឡង់ត៍ ភ្នំពេញ ព្រំប្រទល់ប្រទេសវៀតណាម " តាមបណ្តាញកាប្លិ៍ OPTIC ។

សេវានឹងបានត្រូវផ្គត់ផ្គង់តាមរយៈនៃកិច្ចព្រមព្រៀងជូនបណ្តាក្រុមហ៊ុនការីបណ្តាញទូរគមនាគមន៍ ( Network Operators ) និងអតិថិជនដែលមាន អាជ្ញាប័ណ្ណបំរើសាធារណៈតាមអត្ថន័យ និងលក្ខណ៍ ដូចខាងក្រោម :

**១. អត្ថន័យ :**

១.១- បណ្តាញកាប្លិ៍ OPTIC មានទម្រង់ជាបណ្តាញមួយ ឬច្រើនកំណាត់ ( Segments ) តាមការ សន្មត់គិតពី " ចំណុចមួយទៅចំណុចមួយ : End to End " តាមបណ្តោយផ្លូវជាតិលេខ ៥ និងផ្លូវជាតិលេខ ១ ។

១.២- ការប្រើប្រាស់បណ្តាញកាប្លិ៍ OPTIC ឬការភ្ជាប់បន្តបណ្តាញ ( Interconnection Pount) គឺការតប្រតំបណ្តាញដទៃ១ ( Interf ace ) ដោយភ្ជាប់ចូល ឬ ភ្ជាប់ចេញ នឹងបានត្រូវធានាអំពីអន្តរៈ ភាពប្រតិបត្តិការសេវា ( Interoperability ) ។

**២. ចំណុចភ្ជាប់បន្តបណ្តាញ** ( Interconnection point ) :

២.១- ចំណុចភ្ជាប់បន្ត គឺត្រូវបន្តត្រង់ទៅ " ចំណុចបណ្តាញ " ស្ថិតនៅមជ្ឈមណ្ឌលអង្គរ មហាវិថី សម្តេចព្រះសីហនុ ក្រុងភ្នំពេញ និងតាមបណ្តាស្ថានីយ៍នៅប៉ោយប៉ែត ទីរួមខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ចម្លងអ្នកលឿង ទីរួមខេត្ត ស្វាយរៀង និងស្ថានីយ៍បាវិត . ចំណុចទាំងនោះ អាចជាចំណុចបន្តចូល ( Originating point ) ឬបន្តចេញ ( Terminating Point ) ។

២.២- ចំណុចទាំងនោះសោតក៏អាចបានត្រូវតពន្លាតឆ្ងាយ (ពីមជ្ឈមណ្ឌលអង្គរ និងស្ថានីយ៍ដូចពោលខាងលើ ) ដោយប្រើបណ្តាញក្រុងមានស្រាប់ .

២.៣- ការភ្ជាប់បន្តចំណុចចូល ឬចំណុចចេញរវាងទីតាំងរបស់អ្នកប្រើប្រាស់ គឺការស្ពាបនាខ្សែ ឬបរិបថតប្រតំ ( junction or Interface ) ក្នុងបន្ទុករបស់អ្នកប្រើប្រាស់ ឬដោយការជួលជាវដោយឡែកទៀត ។

៙៙៙

ភ្នំពេញ . ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១

## ប្រកាសលេខ ០៨១ បន.ប្រក.
## ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍
## និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

----

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា